**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៧១៦ ថ្ងៃសុក្រ ទី៣១ ខែកក្កដា ឆ្នាំ២០០៩

# អាជីវកម្មផ្លូវភេទរីកដុះដាលធ្វើឱ្យប៉ះពាល់តំបន់ទេសចរណ៍ វប្បធម៌ និងតំលៃរបស់ស្ត្រីខ្មែរ

ខេត្តសៀមរាប : កន្លែងបំរើផ្លូវភេទ ដោយប្រយោល និងផ្ទាល់បានរីកដុះដាលដូចផ្សិត ស្ទើរតែពាសពេញក្រុងទេសចរណ៍សៀមរាប ដោយពុំមានការយកចិត្តទុកដាក់ទប់ស្កាត់ពីអាជ្ញាធរមានសមត្ថកិច្ចឱ្យបានជិតដល់ទេ និងកំពុងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរគ្រប់រូប និងតំលៃវប្បធម៌មិទំនៀមទំលាប់ជាតិ ។

យោងតាមមន្ត្រីប៉ូលិសមូលដ្ឋានបានឱ្យដឹងថា បច្ចុប្បន្នយ៉ាងហោចណាស់ក៏មានផ្ទះបំរើផ្លូវភេទដោយផ្ទាល់ចំនួន៨ដែរ ក្នុងនោះផ្ទះដែលមានស្ត្រីច្រើនជាងគេ គឺនៅមុខក្លឹបស្នូយ័រផាត់អានផ្សារព៉ៅ និងមួយទៀតនៅផ្ទះល្វែងខាងលិចផ្ទះសំណាក់យីហោកុលាបក្រហម ចំងាយប្រមាណ៣០ម៉ែត្រ ស្ថិតនៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប និងនៅម្តុំចំណតរថយន្តចុងកៅស៊ូ ។ ក្រៅពីផ្ទះបំរើផ្លូវភេទដោយផ្ទាល់ នៅមានទីតាំងបំរើផ្លូវភេទដោយប្រយោលរាប់សិបកន្លែងទៀតដែលបង្កប់តាមក្លឹបរាត្រី និងហាងខារ៉ាអូខេ ។

តាមក្រុមបុរសដែលឧស្សាហ៍ដើរលេងក្រៅផ្ទះពេលយប់និយាយថា ស្ត្រីបំរើផ្លូវភេទដោយផ្ទាល់ ភាគច្រើនជាជនជាតិវៀតណាម ដែលមានតំលៃចាប់ពី៣ដុល្លារដល់៥ដុល្លារ សំរាប់បំរើលើគ្រែមួយលើក១ ។ ចំណែកស្ត្រីបំរើផ្លូវភេទដោយប្រយោលជាក្រុមស្ត្រីបំរើស្រាបៀរ ស្ត្រីបំរើសេវាតាមក្លឹប និងហាងខារ៉ាអូខេ ភាគច្រើនជាជនជាតិខ្មែរមានតំលៃខ្លួនចាប់ពី២៥ដុល្លារឡើងទៅ សំរាប់ការរួមភេទជាមួយបុរសជាដៃគូ១លើក១ ។

អាជីវកម្មបំរើផ្លូវភេទដោយប្រយោល និងផ្ទាល់នោះ វាមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរគ្រប់រូប និងតំលៃវប្បធម៌ជាតិប៉ុណ្ណោះទេ វាថែមទាំងបានក្លាយជាសេចក្តីខ្វល់ខ្វាយរបស់ស្ត្រីជាឧត្តមភរិយា និងជាម្តាយដែលមានស្វាមី និងកូនចូលចិត្តសប្បាយភ្លើតភ្លើនបែបនោះ ។ ស្ត្រីម្នាក់រស់នៅក្រុងសៀមរាបថ្លែងថា សម័យនេះការប្រចណ្ឌប្តីដែលទៅមានស្រីក្រៅផ្ទះវាពុំជាប៉ុន្មានទេ ប៉ុន្តែការព្រួយបំផុត គឺការប្រឈមនឹងការចំលងវីរុសអេដស៍មកដល់ក្រុមគ្រួសារតែម្តង ។

យោងតាមរបាយការណ៍បូកសរុបការងារឆមាសទី១ ឆ្នាំ២០០៩ របស់មន្ទីរទេសចរណ៍ខេត្តសៀមរាបបានបង្ហាញឱ្យឃើញថា ហាងម៉ាហ្សាមានចំនួន៣៥កន្លែង និងហាងខារ៉ាអូខេមានចំនួន១៥កន្លែង នៅពាសពេញទីក្រុងសៀមរាប ។ ហាងមួយចំនួន

ត្រូវបានរាយការណ៍ថា មានបន្ទប់សំរាប់លួចលាក់បំរើផ្លូវភេទ ឬអាចហៅទៅផ្ទះសំណាក់រួមភេទបានតាមការព្រមព្រៀង។ អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប លោក រី អញ្ចលី មានប្រសាសន៍តាមទូរស័ព្ទកាលពីថ្ងៃទី២៩ កក្កដា ២០០៩ ថា តួនាទីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺប៉ូលិសការិយាល័យប្រឆាំងការជួញដូរមនុស្ស ជាអ្នកអនុវត្តផ្ទាល់។ ការបណ្តែតបណ្តោយឱ្យមានហាងស្រ្តីបំរើផ្លូវភេទនៅពាសពេញទីក្រុងទេសចរណ៍សៀមរាបដែលសំបូរទៅដោយភ្ញៀវទេសចរជាតិ អន្តរជាតិ រាប់សែននាក់ក្នុងមួយឆ្នាំ។ ដូច្នេះវាបានអូសទំលាក់តំលៃថ្លៃថ្នូររបស់ស្រ្តីខ្មែរ និងប៉ះពាល់ដល់តំលៃវប្បធម៌ ជាតិយ៉ាងធ្ងន់ធ្ងរបំផុត ។

សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានផ្តល់អនុសាសន៍ថា មិនឱ្យមានទេសចរណ៍ផ្លូវភេទឡើយ ក៏ប៉ុន្តែអ្វីដែលជាការចន្លោះប្រហោងសំរាប់អាជ្ញាធរក្រុងទេសចរណ៍សៀមរាបនោះ គឺគេនៅតែឃើញទីតាំងបំរើផ្លូវភេទយ៉ាងច្រើនស្អេកស្កះដដែល ។ ប្រជាពលរដ្ឋបានលើកឡើងថា កន្លងមកធ្លាប់ឃើញសមត្ថកិច្ចដំឡើងសាច់ដុំបង្ក្រាបផ្ទះស្រ្តីបំរើផ្លូវភេទម្តងម្កាលដែរ ប៉ុន្តែបន្ទាប់មកស្ងប់ស្ងាត់ទៅវិញ។ លោក បឹង ពេជ្រ ប្រធានការិយាល័យសុខុមាលភាពសង្គមនៃមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តសៀមរាប បានថ្លែងថា តាមរបាយការណ៍ដែលបានកត់ត្រាទុកកន្លងមកឃើញថា មានស្រ្តីបំរើផ្លូវភេទជាច្រើនត្រូវសមត្ថកិច្ចប៉ូលិសនាំយកទៅអប់រំកែប្រែ រួចបញ្ជូនមកឱ្យមន្ទីរដើម្បីស្វែងរកអង្គការ ជាដៃគូជួយបណ្តុះបណ្តាលជំនាញ ដូចជាកាត់ដេរសំលៀកបំពាក់ និងអ៊ុតសក់ជាដើម សំរាប់ជំនួសរបរចាស់របស់ពួកនាង។ ទោះជាយ៉ាងណាក្តីការតាមដានឃើញថា ស្រ្តីដែលសង្គ្រោះចេញពីផ្ទះបនភាគច្រើនបានវិលត្រឡប់ទៅរកផ្លូវចាស់ខ្លួនវិញ ជាពិសេសស្រ្តីជនជាតិវៀតណាម ព្រោះគេគិតថា មុខរបរនោះងាយរកលុយ ។ យោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ២០០៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទំរង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១៨ មករា ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ត្រង់ជំពូកទី៤ មាត្រា២៦បានចែងថា "ជនណាដែលប្រព្រឹត្តសញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំដល់៥ឆ្នាំ" ។ ប៉ុន្តែច្បាប់នេះ ក្រុមមន្ត្រីអនុវត្តច្បាប់នៅមិនទាន់បានយកទៅអនុវត្តឱ្យបានប្រសើរនៅឡើយ។

អភិបាលក្រុងសៀមរាប លោកទេព ប៊ុនឆាយ ក្រោយពីបានស្តាប់សេចក្តីរាយការណ៍ជុំវិញរឿងផ្ទះស្រ្តីបំរើផ្លូវភេទរីកដុះដាលដូចផ្សិត នៅក្នុងដែនដីគ្រប់គ្រងរបស់លោកមក លោកមានប្រសាសន៍ថា "នឹងឱ្យមន្ត្រីប៉ូលិសក្រោមឱវាទ ចុះទៅពិនិត្យ" ។